អង្គរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ

## ក្រោមប្រធានបទ សំនួរនិងចម្លើយស្តីអំពីសិទ្ធិមនុស្ស (តពីលេខមុន)

www.hoksavann.org

ថ្ងៃទី២ តុលា ២០១២



៥- សំនួរ ៖ អត្ថន័យរបស់សិទ្ធិមនុស្សគឺអ្វី ហើយនៅឯណា ?

ចម្លើយ ៖ អត្ថន័យសំខាន់បំផុតរបស់សិទ្ធិមនុស្សសំរាប់ពិភពលោកបច្ចុប្បន្ននេះ មានថែងទាំងស្រុងនៅក្នុង «សេចក្តីថ្លែងការណ៍សាកលស្តីអំពីសិទ្ធិមនុស្ស» ដែលត្រូវប្រកាសឡើងដោយមហាសន្និបាតអង្គការសហប្រជាជាតិ នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ ។ សេចក្តីប្រកាសនេះបានកំណត់ជាស្តង់ដាទូទៅនៃការសំរេចផល (សមិទ្ធិកម្ម) ជូនគ្រប់ជាតិនិងគ្រប់ពលរដ្ឋ។

ជាង១០ឆ្នាំកន្លងទៅនេះ ប្រការជាច្រើននៃសេចក្តីប្រកាសជាសាកលនេះ បានត្រូវគេស្រង់យកមកពិភាក្សា និងចងក្រងឲ្យស្របតាមលំនាំច្បាប់អន្តរជាតិ ។ ដូច្នេះបើនិយាយជាភាសាច្បាប់ សេចក្តីប្រកាសជាសាកលនេះត្រូវមានឈ្មោះថា «កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ» ហើយនិងមួយបែបទៀតឈ្មោះ «កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិខាងវិស័យសង្គម សេដ្ឋកិច្ច និងវប្បធម៌» ។ កតិកាមានន័យថា «ការព្រមព្រៀងគ្នាជាឧឡារិក» ។

ទាំងបីបែបនេះរួមគ្នា ពោលគឺ សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្ស, កតិកាសញ្ញាអន្តរជាតិស្តីអំពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ហើយនិងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិខាងវិស័យសង្គម សេដ្ឋកិច្ច និងវប្បធម៌ មានឈ្មោះថា «កំរងច្បាប់សិទ្ធិមនុស្សអន្តរជាតិ» ។

នៅមានកំរងសិទ្ធិមនុស្សដ៏សំខាន់ៗខ្លះទៀត ជាពិសេសសំរាប់ក្រុមដែលតែងតែរងគ្រោះដោយសារអ្នកឯទៀត ។ សំរាប់ពលរដ្ឋជំពូកនេះ គេបានចងក្រងច្បាប់បន្ថែមនៅក្នុងច្បាប់អន្តរជាតិស្តីអំពីសិទ្ធិមនុស្ស ។ ឧទាហរណ៍ដូចជា អនុសញ្ញាស្តីអំពីសិទ្ធិនារី និងអនុសញ្ញាស្តីអំពីសិទ្ធិកុមារ ។

មានកំរងច្បាប់សិទ្ធិមនុស្សផ្សេងៗទៀតដូចជា ៖ អនុសញ្ញាប្រឆាំងទារុណកម្មនិងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬនាំឲ្យបាត់បង់តម្លៃជាមនុស្ស, អនុសញ្ញាស្តីអំពីការបង្ការ និងផ្តន្ទាទោសបទឧក្រិដ្ឋនៃការប្រល័យពូជសាសន៍, អនុសញ្ញាអន្តរជាតិស្តីអំពីការបំបាត់ចោលសព្វបែបយ៉ាងនៃការប្រកាន់ពូជសាសន៍, សេចក្តីថ្លែងការណ៍ស្តីអំពីការបំបាត់នៃទំរង់នៃការមិនអនុគ្រោះ និងការរើសអើងខាងវិស័យសាសនា និងជំនឿ, វិន័យនិងបទបញ្ជាចាំបាច់សំរាប់គ្រប់គ្រងអ្នកទោស និងបទវិន័យសំរាប់ភ្នាក់ងារទទួលបន្ទុកខាងកិច្ចប្រតិបត្តិច្បាប់ជាដើម ។

សេចក្តីថ្លែងការណ៍និងអនុសញ្ញាសិទ្ធិមនុស្សដែលកំណត់យ៉ាងជាក់ច្បាស់អំពីសិទ្ធិមនុស្ស និងការរំលោភសិទ្ធិមនុស្ស ទាំងនោះបានត្រូវសន្ធិសញ្ញាសន្តិភាពឲ្យឈ្មោះថា «កំរងច្បាប់អន្តរជាតិស្តីអំពីសិទ្ធិមនុស្ស» ភាគសំខាន់ៗនៃសេចក្តីថ្លែងការណ៍ ហើយនិងអនុសញ្ញាជាច្រើនបានត្រូវប្រែជាភាសាខ្មែរ ដោយគណៈកម្មាធិការប្រមូលឯកសារស្តីពីកម្ពុជា ។ សូមមើលទៅសេចក្តីបន្ថែមនៅខាងចុង...

៦- សំនួរ ៖ តើសិទ្ធិមនុស្សជាកម្មសិទ្ធិរបស់ពួកបស្ចឹមប្រទេស ឬរបស់ពិភពលោកទាំងមូល ?

ចម្លើយ ៖ សិទ្ធិមនុស្សជារបស់សាកលនិងអន្តរជាតិ ដោយសារប្រទេសនានាប្រចាំទ្វីបអាស៊ី, អាហ្វ្រិក, អាមេរិកឡាទីនព្រមទាំងទ្វីបអឺរ៉ុប និងអាមេរិកភាគខាងជើង បានរួមចំណែកក្នុងសេចក្តីថ្លែងការណ៍អន្តរជាតិ ហើយនិងកតិកាសញ្ញា និងអនុសញ្ញានានា ដែលកំណត់យ៉ាងច្បាស់លាស់អំពីសិទ្ធិមនុស្ស ។

ប៉ុន្តែនៅមានអ្នកខ្លះភ័ន្តច្រឡំពីរឿងនេះ ព្រោះគេយល់ពុំច្បាស់ អំពីកំរងពាក្យពេចន៍នៃសិទ្ធិមនុស្ស, ប្រវត្តិនៃសិទ្ធិមនុស្ស ហើយនិងខ្លឹមសាររបស់សិទ្ធិមនុស្ស ។

ភាសាទំនើបស្តីអំពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដែលបានចងក្រងឡើងនៅក្នុងពេល ដែលកំពុងមានការកែទំរង់នយោបាយឲ្យទាន់សម័យ ពោលគឺការផ្លាស់ប្តូរទៅជារដ្ឋសម័យទំនើប ចេញពីមហាចក្រភព ដែលមានប្រទេសនិងជាតិជាច្រើន ស្ថិតនៅក្រោមការគ្រប់គ្រងនៃស្តេច ឬអធិរាជតវង្សត្រកូលគ្នា ។ សិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយថែងជាកំរងច្បាប់សំរាប់គ្រប់គ្រង ដល់ទំនាក់ទំនងរវាងអាជ្ញាធរនយោបាយ និងពលរដ្ឋនៃប្រទេសជាតិដែលមានឯករាជ្យ ។

រីឯកំរងច្បាប់សិទ្ធិខាងវិស័យសេដ្ឋកិច្ចនិងសង្គមវិញ គេចងក្រងឡើងដើម្បីឆ្លើយតបទៅនឹងការបដិវត្តន៍តិកណូឡូស៊ី ( បច្ចេកវិជ្ជា) នៃឧស្សាហូបនីយកម្មជាន់ដំបូង ដើម្បីញ៉ាំងឲ្យពលរដ្ឋនៃប្រទេសទាំងនោះបានទទួលផលអំពីការរីកចំរើនខាងផលិតកម្មនៃបច្ចេកវិជ្ជាទំនើប ។

នវូបនីយកម្មនយោបាយ (ការធ្វើឲ្យទំនើប) និងអភិវឌ្ឍន៍ (ការរីកចំរើន) ឧស្សាហកម្មសេដ្ឋកិច្ចចាប់ផ្តើមឡើងនៅទ្វីបអឺរ៉ុបនិងអាមេរិកខាងជើងក្នុងសតវត្សរ៍ទី១៨និង១៩ ។ នៅប្រទេសខ្មែរ ហើយនិងប្រទេសភាគច្រើននៃអាស៊ីអាគ្នេយ៍ នវូបនីយកម្មនយោបាយពុំទាន់អាចធ្វើទៅបាន រហូតទាល់តែប្រទេសអស់ទាំងនេះបានឯករាជ្យអំពីនឹមអាណានិគមនៃពួកអឺរ៉ុបចាប់ពីឆ្នាំ១៩៥០មក ។ ប៉ុន្តែក្បួនច្បាប់វិន័យក្នុងការអនុវត្តន៍សិទ្ធិមនុស្សដែលចងក្រងឡើងដោយប្រទេសឯករាជ្យជាច្រើននៅអង្គការសហប្រជាជាតិនោះ គឺសំរាប់ឲ្យប្រទេសទាំងអស់ទូទៅទាំងពិភពលោកប្រើបានដូចគ្នា ។

(នៅមានត)